# ការសំភាសន៍របស់ សឿ ខា

កះ អ្នកដែរសំភាសន៍ ជាង ស៊ីអាវ ខះ អ្នកដែរអោយគេសំភាសន៍ សឿ ខា

កះ ចឹងជាចំបូងខ្ញុំសូមជំរាបសួរមីង
ហើយអរគុណច្រើនមីងដែរបានអោយបានសំភាសន៍ពីប្រវត្តិរបស់មីង
ហើយការសំភាសន៍ត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះBYU ហាសមីង
ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ
ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗដើម្បីអោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងដូចតាចឹងហាសមីង
ចឹងពេលដែរខ្ញុំសំភាសន៍មីងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាហាសមីង ដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង
បាទចឹងតើមីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខះ មានអីព្រមតា

កះ បាទចឹងមីងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ
ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងនៅថ្ងៃទី26 ខែ1 ឆ្នាំ2018ចឹងហាសមីង
ចឹងធ្វើនៅភូមិ4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញចឹងហាសមីង
ចឹងសំរាប់មីងឈ្មោះពេញរបស់មីងមានឈ្មោះអីគេដែរចឹងហាសាមីង?

ខះ មានឈ្មោះ សុខា

កះ ស្អីគេទៅសុខាមីង?

ខះ ឈ្មោះ សឿ

កះ ឈ្មោះ សឿ សុខា ចុះមីងមានឈ្មោះហៅក្រៅទេមីង?

ខះ អត់មានទេមានតែឈ្មោះមួយនឹង

កះ មានតែឈ្មោះមួយនឹងទេណមីង
ចុះកាលពីក្មេងធ្លាប់មាននរណាគេហៅមីងអីផ្សេងទៀតអត់មីង?

ខ៖ អត់ទេ

ក៖ អត់ទេណាមីង ចុះសព្វថ្ងៃមីងអាយុប៉ុន្មានដែរមីង?

ខ៖ ខ្ញុំអាយុ48ឆ្នាំហើយ

ក៖ ចុះមីងមានចាំថាមីងកើតនៅខែណា ឆ្នាំណា ថ្ងៃណាដែរទេមីង?

ខ៖ កើតនៅឆ្នាំ1973

ក៖ ឆ្នាំ1973 ចុះខែមីងមានចងចាំទេ?

ខ៖ ខែស្អីគេខ្ញុំនេះ ដឹងតែកើតនៅឆ្នាំ1973នេះ

ក៖ ចុះមីងឆ្នាំច័ន្ទគតិមីងមានឆ្នាំអីគេដែរមីង ឆ្នាំជូត ឆ្លូវ ខាល ថោះហាសមីង?

ខ៖ ខ្ញុំឆ្នាំជូត

ក៖ ឆ្នាំជូតណាមីង ចុះមីងកើតនៅណាដែរមីង នៅភូមិអី ឃុំអី ស្រុកអី ខេត្តអីចឹងហាស?

ខ៖ កើតនៅភូមិអើរ បើស្រុកកំណើតខ្ញុំនៅព្រៃវែង

ក៖ នៅព្រៃវែងហោស ប៉ុន្តែនៅភូមិអី ឃុំអីមីងមានចងចាំទេ?

ខ៖ ឃុំកំពុងអំពិល

ក៖ ចុះភុមិវិញមីង?

ខ៖ ឃុំកំពុងអំពិលដែរនឹង

ក៖ ចុះស្រុកវិញមីង?

ខ៖ នៅស្រុកពារាំង

ក៖ នៅស្រុកពារាំងខេត្តព្រៃវែងណាមីង
ចុះមីងផ្លាស់ទីលំនៅទៅនៅខេត្តកំពុងសោមយូរនៅមីង?

ខ៖ យូរដែរហើយនឹង

ក៖ ដូចជាប៉ុន្មានឆ្នាំដែរមីង?

ខ៖ វាជាង10ឆ្នាំហើយនឹង

ក៖ អូជាង10ឆ្នាំហោស ដល់ពេលនឹងបានមីងមកនៅភ្នំពេញវិញ?

ខ៖ ដល់ពេលដែរកូនមករៀននៅទីនេះ ក៏ខ្ញុំមកធ្វើការងារនៅទីនឹងទៅ

ក៖ អូមកនៅយូរនៅមីង?

ខ៖ មកនៅជាង4-5ខែហើយ កូនរបស់ខ្ញុំមកនៅភ្នំពេញជាង2ឆ្នាំហើយនឹង

ក៖ អូប៉ុន្មានមីងនឹងនៅនឹងយូរមែនទេ?

ខ៖ ចានៅនឹងយូរ

ក៖ ចឹងសំរាប់មីងមានបងប្អូនប៉ុន្មាននាក់ដែរមីង?

ខ៖ ខ្ញុំមានបងប្អូន5នាក់

ក. ចុះមីងមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរមីង?

ខ៖ មានស្រី2នាក់

ក៖ ចឹងប្រុស3នាក់ណាមីង ចុះមីងជាកូនទីប៉ុន្មានដែរមីង?

ខ៖ ខ្ញុំជាកូនទី2

ក៖ អូជាកូនទី2ហោសមីង
ចុះមីងអាចប្រាប់ខ្ញុំបានទេថាឈ្មោះបងប្អូនរបស់មីងមានឈ្មោះអីគេខ្លះដែរទេមីង?

ខ៖ ឈ្មោះហោស បងគេឈ្មោះ ខន

ក៖ ចុះទី2នឹងមីង?

ខ៖ ទី2គឺខ្ញុំនឹង

ក៖ ចុះទី3វិញមីង?

ខ៖ ឈ្មោះ ពុំ

ក៖ ចុះទី4វិញមីង?

ខ៖ ទី4 ឈ្មោះ ពុធ

ក៖ ចុះទី5វិញមីង?

ខ៖ ទី5នឹងឈ្មោះធា

ក៖ នឹងកូនពៅណាមីង?

ខ៖ ធានឹងពៅគេហើយ

ក៖
ចុះមីងមានចងចាំសាច់រឿងអីជាមួយបងប្អូនរបស់មីងកាលពីមីងនៅក្មេងអីថាកាលពីនៅក្មេងៗមីងធ្លាប់បានធ្វើអីគេចឹងហាស?

ខ៖ ខ្ញុំធ្លាប់កាលពីក្មេងៗខ្ញុំដើរស៊ីឈ្នួលអោយគេ
យើងធ្វើការអោយគេចឹងហាសយើងអត់មិនយើងដើរធ្វើការងារអោយគេស្មានេះយើងមិនទាន់ចូលផ្ទះផងនឹង យើងដើរដក ដើរស្ទូងស៊ីឈ្នួលអោយគេចឹងទៅណា

ក៖ ចុះកាលពីក្មេងៗមីងមានធ្លាប់លេងឡឹកបាយឡអីជាមួយបងប្អូនរបស់មីងទេ?

ខ៖ មានការលេងឡឹកបាយឡ លេងពួន លេងអីចេះតែលេងទៅ

ក៖ លេងមឹកលេងអីចឹងទៅហោសមីង?

ខ៖ នឹងហើយចេះតែលេងហើយ

ក៖ ចុះមីងមានធ្លាប់ទៅស្រែអីជាមួយគាត់ទេ?

ខ៖ ធ្លាប់ទៅតា

ក៖ ចុះទៅស្រែមីងទៅជាមួយបងប្អូនរបស់មីងទៅធ្វើអីគេដែរទៅមីង?

ខ៖ ទៅស្ទូង ទៅដក សំណាបនឹង

ក៖ ទៅស្ទូងនឹងទៅដក
កាលពីជំនាន់ណុងមីងអាយុប្រហែលជាប៉ុន្មានទៅជាមួយពួកគាត់ហាសមីង?

ខ៖ អាយុប្រហែលជា17ឆ្នាំអីនឹង

កៈ អូអាយុ17-18ឆ្នាំហើយហោស
ចុះមីងគិតថាកាលពីនៅក្មេងតើមីងចូលចិត្តលេងអីជាមួយបងប្អូនរបស់មីងដែរ?

ខៈ ចូលចិត្តលេងល្បែង

កៈ អូលេងល្បែងហោសមីង?

ខៈ នឹងហើយចូលចិត្តលេងល្បែងនឹង

កៈ អូមីងចេះលេងល្បែងហោសមីង?

ខៈ ចាចេះតា

កៈ ចុះបងប្អូនរបស់មីងពួកគាត់ចេះលេងដែរ?

ខៈ ចេះតែលេងៗទៅយើងនៅក្មេងដើរតួល្បែងបេះផ្លែឈើ
ស្អីៗយកមកដាក់ផ្កាចឹងហាសណា

កៈ អូបាទមីង ប៉ុន្តែមីងធ្លាប់បានរៀមនល្បែងពីមុនមែនមីង?

ខៈ ខ្ញុំអត់ផងនឹង ប៉ុន្តែគ្រាន់តែខ្ញុំចូលចិត្តល្បែង
សូម្បីតែសព្វថ្ងៃនឹងក៏ចឹងដែរអោយតែល្បែងនឹងទៅមើលហើយចូលចិត្តមើលហាស

កៈ អូបាទមីងចុះ បងប្អូនរបស់មីងសព្វថ្ងៃនឹងគាត់នៅណាដែរមីង?

ខៈ នៅខេត្តកំពុងសោមទាំងអស់គ្នា

កៈ
ពួកគាត់នៅកំពុងសោមទាំងអស់គ្នាចឹងមានន័យថាមីងនៅតែភ្នំពេញនឹងតែម្នាក់អែងទេណាមីង?

ខៈ ខ្ញុំនៅតែម្នាក់អែងទេ

កៈ ក្តៅពីនឹងពួកគាត់ទៅនៅកំពុងសោមហោសមីង?

ខៈ ចានឹងហើយ

កៈ ចុះពួកគាត់ធ្វើអីគេនៅកំពុងសោមនឹងហោសមីង?

ខ៖ ធ្វើចំការ

ក៖ ទាំងអស់គ្នាតែម្តង?

ខ៖ ចានឹងហើយ

ក៖ ចុះអត់មាននរណាគេមានលក់គ្រឿងសមុទ្រ រឺក៏លក់ដូរអីទេណាមីង?

ខ៖ អត់សោះ

ក៖ ចុះពួកគាត់នៅទីរួមខេត្តរឺមួយក៏នៅតាមស្រុកដែរមីង?

ខ៖ នៅហួសស្រែអំបិលយើងនឹងតិចនឹង

ក៖ អូស្រែអំបិលផ្លូវបុកទៅផ្លូវកោះកុងនឹងមែនមីង?

ខ៖ នឹងហើយតាមផ្លូវនឹង

ក៖ ចុះម្តាយរបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់មានឈ្មោះ អឿន គាត់ស្លាប់បាត់ហើយ

ក៖ ចុះឪពុកវិញមីង?

ខ៖ ឈ្មោះ ពោន

ក៖ ឈ្មោះ ពោន ចុះមីងមានដឹងថាឪពុករបស់មីងអាយុប៉ុន្មានដែរទេមីង?

ខ៖ ឪពុករបស់ខ្ញុំអាយុ63ឆ្នាំ

ក៖ គាត់អាយុ63ឆ្នាំ ចុះគាត់កើតនៅឆ្នាំណាមីងមានដឹងទេ?

ខ៖ អត់ដឹងដែរនឹង ខ្ញុំគ្រាន់តែដឹងថាម៉ែរបស់ខ្ញុំនិយាយថាអាយុ63ឆ្នាំថាតាមគាត់ដែរទេ

ក៖ ចុះម្តាយរបស់មីងអាយុប៉ុន្មានដែរមីង?

ខ៖ ម្តាយរបស់ខ្ញុំអាយុ56ឆ្នាំ

ក៖ ចុះឪពុករបស់មីងនឹងម្តាយរបស់មីងគាត់កើតនៅណាដែរមីងមានដឹងទេ?

ខ៖ គាត់កើតនៅព្រៃវែង

កៈ ចុះមីងមានដឹងថាឪពុកម្ដាយរបស់មីងគាត់កើតនៅណាដែរទេមីង?

ខៈ គាត់កើតនៅព្រៃវែង

កៈ ទាំងម្ដាយ ទាំងឪពុកនឹងហោសមីង?

ខៈ ចាទាំងពីរនឹង

កៈ ចុះឆ្នាំច័ន្ទគតិមីងមានដឹងថាពួកកើតនៅឆ្នាំអីគេទេ?

ខៈ ម៉ែរបស់ខ្ញុំឆ្នាំអីទេនេះភ្លេចបាត់ហើយនឹង អត់ដឹងដែរភ្លេចបាត់ហើយម៉ែរបស់ខ្ញុំនឹង

កៈ អូចុះឪពុកវិញមីង?

ខៈ ខ្ញុំអត់ដឹងដែរនឹង

កៈ អូអត់ដឹងទេណាមីង?

ខៈ ខ្ញុំចាំតែគាត់អាយុប៉ុណ្ណឹងអែង

កៈ អត់អីទេមីង ចុះឪពុករបស់មីងគាត់ធ្លាប់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតហាសមីង?

ខៈ គាត់ហាសដាក់ម៉ង ដាក់ស្ទឹៗចឹងទៅ គាត់ដូចតែថារកត្រី
រកម្ហូបអាហារចឹងហាសគាត់ទៅបឹងទៅអីចឹងទៅណា

កៈ ចុះគាត់ជាមនុស្សយ៉ាងម៉េចដែរមីងស្លូត រឺមួយកាចដែរមីង?

ខៈ ប៉ារបស់ខ្ញុំគាត់ស្លូតដែរនឹង

កៈ អូបាទចុះម្ដាយរបស់មីងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ គាត់ស្ទូង ធ្វើស្រូវ ធ្វើស្រែចឹងហាសណា

កៈ អូបាទចុះគាត់ជាមនុស្សបែបណាដែរមីង?

ខៈ ម៉ែរបស់ខ្ញុំគាត់ស្លូតដែរនឹង

កៈ គាត់ស្លូតណាមីង
ចុះមីងមានចងចាំសាច់រឿងអីកាលពីមីងនៅជាមួយឪពុកម្ដាយរបស់មីងទេ
ថាមីងធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់ចឹងហាស?

ខៈ ខ្ញុំថ្លាប់ទៅចំការអីជាមួយគាត់ចឹងហាស ទៅស្ទូង
ទៅដកចេះតែទៅជួយគាត់ចឹងហាសម៉ែហៅទៅនឹងឪចឹងអត់បានរៀន
នឹងហើយយើងឃើញម៉ែឪអត់ចឹងយើងចេះតែទៅជួយហាស

កៈ
បាទមីងចុះម្ដាយឪពុករបស់មីងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅមីងទេ?

ខៈ កាលពៅក្មេងម៉ែរបស់ខ្ញុំលឺគាត់និយាយថាឪពុករបស់ខ្ញុំធ្វើជាទាហ៊ាន

កៈ អូគាត់ធ្វើជាទាហ៊ានហោសមីង?

ខៈ កាលពីជំនាន់ពលពតនឹងគាត់ធ្វើជាទាហ៊ានហោសមីង
ដល់ពេលនឹងទៅគេទៅធ្វើអីទេគេបានចាប់គាត់ចងទៅ
គាត់អត់បាយអត់ទឹកចង់ស្លាប់ចង់រស់ហើយ
បានម្ដាយរបស់ខ្ញុំគាត់លួចយកបាយយកអីទៅអោយហូបចឹងហាសណា

កៈ ចុះប្រវត្តិម្ដាយគាត់មានធ្លាប់ប្រាប់ថាគាត់ធ្លាប់ធ្វើអីទេ?

ខៈ ម៉ែរបស់ខ្ញុំគាត់ធ្វើចុងភៅនៅជំនាន់ពលពតនឹងបានយើងបែកណា
ដល់ពេលគាត់ធ្វើឪពុករបស់ខ្ញុំចឹងទៅគាត់ចេះតែលួចបាយមូលចង្កេះខោយកទៅអោយគាត់ហូបចឹងទៅណា លឺតែគាត់និយាយនឹង

កៈ ចុះយាយតាខាងម្ដាយមីងមានស្គាល់ឈ្មោះគាត់ថាគាត់មានឈ្មោះអីទេ?

ខៈ យាយតាខាងម្ដាយខ្ញុំអត់ចាំដែរនឹងពីព្រោះខ្ញុំកើតមកឃើញតែម្ដាយរបស់ខ្ញុំនឹងអែង

កៈ អូយាយតាខាងម្ដាយមីងអត់ស្គាល់ឈ្មោះគាត់ទេណាមីង?

ខៈ ខ្ញុំលឺតែថាមានឈ្មោះ អែម

កៈ នឹងយាយ?

ខៈ ចាយាយខាងម៉ែរបស់ខ្ញុំហាស

កៈ ចុះតាវិញមីង?

ខៈ តាឈ្មោះ សឿ

កៈ ចុះយាយតាខាងឪពុកវិញ?

ខៈ ខ្ញុំអត់ដឹងទេ

កៈ អត់ស្គាល់ឈ្មោះគាត់ទេ?

ខៈ ពីព្រោះគាត់បានឪពុករបស់ខ្ញុំនឹងនៅជាមួយគេហាស
នៅជាមួយគេទៅបានដន្លឹងម្ដាយរបស់ខ្ញុំការហើយ
កាលណុងម៉ែបែកម៉ែបែកឪអស់ហើយណា

កៈ ចុះមីងមានដឹងថាយាយតាខាងម្ដាយគាត់កើតនៅណាអត់មីង?

ខៈ គាត់កើតនៅព្រៃវែងដែរនឹង

កៈ គាត់កើតនៅព្រៃវែងដែរហោសមីង ប៉ុន្តែគាត់អាយុប៉ុន្មានមីងដឹងទេ
ហើយគាត់កើតឆ្នាំអីចឹងហាសមីងមានចងចាំទេ ?

ខៈ កាលពីយាយរបស់ខ្ញុំស្លាប់នឹងអាយុ70ឆ្នាំ

កៈ គាត់អាយុ70ឆ្នាំហោស ប៉ុន្តែគាត់ស្លប់នឹងដូចជាប៉ុន្មានឆ្នាំហើយមីង?

ខៈ ហេដូចជាយូរដែរហើយនឹងប្រហែលជា20-30ឆ្នាំហើយនឹង

កៈ អូចឹងមានន័យថាគាត់ប្រហែលជាអាយុ90-100ឆ្នាំអីហើយណាមីង?

ខៈ អត់ដឹងដែរនឹងគាត់ស្លប់យូរដែរហើយនឹង

កៈ ចុះមីងទៅនៅកំពុងសោមប្រហែលជាប៉ុន្មានឆ្នាំទៅមីង?

ខៈ ខ្ញុំទៅនៅកាលពីអាពតគេត្រូវគ្នានឹង ខ្ញុំទៅចាប់ដីនៅណុងហាស

កៈ អូចឹងមានន័យថាប្រហែលជាង30-40ឆ្នាំហើយណាមីង?

ខៈ ចានឹងហើយ

កៈ រហូតមកដល់ពេលដែរមកនៅភ្នំពេញវិញប្រហែលជាជាង40ឆ្នាំហើយណាមីង?

ខៈ តាំងពីកូនរបស់ខ្ញុំមីមួយតូចនឹង5-6ខែហើយ តែឥឡូវនឹងវាអាយុ18ឆ្នាំហើយ

កៈ ចឹងវាខ្ទង់ប៉ុណ្ណឹងជិត20ឆ្នាំហើយ?

ខ៖ នឹងហើយឥឡូវនឹងវាអាយុ18ឆ្នាំហើយ

ក៖ អូបាទចុះមីងមានបងប្អូន រឺសាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេស
ក្រៅពៅស្រុកខ្មែរទេមីង?

ខ៖ អត់មានផងនឹង

ក៖ មានតែនៅខ្មែរទេណាមីង?

ខ៖ ចាអត់មានទេ

ក៖ ចុះប្តីរបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ ប្តីរបស់ខ្ញុំគាត់មានឈ្មោះ ហុង

ក៖ គាត់ឈ្មោះ ហុង
ចុះមីងមានចងចាំថាគាត់រៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេមីង?

ខ៖ ខ្ញុំអត់បានការបានអីទេ ដូចថាយើងស្រលាញ់គ្នាចឹងហាស
ដល់ហើយយើងចេះតែមានជាកូនជាចៅទៅឥឡូវនឹងគាត់ស្លាប់បាត់ទៅហើយនឹង

ក៖ ចុះពេលដែរមីងស្រលាញ់គ្នានឹងដូចជាមានរៀបចំអីគេទេមីង?

ខ៖ គ្រាន់តែសែនបន្តិចបន្តួចដែរ

ក៖ ប៉ុន្តែយល់ស្របទាំងសងខាងណមីង?

ខ៖ ចាយល់ស្របតា ប៉ុន្តែម៉ែឪរបស់គេនៅឆ្ងាយអត់បានមកទេ គេមកតែខ្លួនគេទេណា

ក៖ ប៉ុន្តែពេលណុងប្តីរបស់មីងមានជាជំនូនអោយទេ?

ខ៖ អត់ផងនឹង

ក៖ អត់មានទេណមីង?

ខ៖ គ្រាន់តែសែនក្បាលជ្រូកពីជីដូនជីតាអីចឹង មានការដឹងលឺតិចតួចអីចឹងទៅណា

ក៖ ចុះមីងអាចប្រាប់បីពេលដំបូងថាមីងបានជួបជាមួយស្វាមីរបស់មីងពេលណា
ហើយហេតុអីបានជាមីងស្រលាញ់គ្នាអីចឹងហាសមីង?

ខ៖ ភ្លេចអស់ហើយនេះនឹងយូរដែរហើយនឹង

ក៖ ដូចជាស្រលាញ់គ្នាយូរនៅបានគាត់?

ខ៖ យើងស្រលាញ់គ្នាយូរដែរនឹងហាសបានយើងបានគ្នានឹងហាស
សុទ្ធអ្នកងត់ដូចគ្នាចឹងហាសណា

ក៖ បាទចុះមីងចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរមីង?

ខ៖ ខ្ញុំអត់ចេះទេនេះចឹងបានថាខ្ញុំអត់សូវបានចូលសាលាទេមកពីខ្ញុំនឹងអត់

ក៖ អូបាទចឹងមីងអត់បានរៀនទេណាមីង?

ខ៖ ទៅរៀនចឹងទៅគេចសាលាចឹងទៅ ជយយដក
ស្ទូងម៉ែឪចឹងទៅវាមិនបានចូលសាលាទេ

ក. បាទមីងចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរទេមីង?

ខ៖ អត់ទេ

ក៖ ភាសាអង់គ្លេស ភាសាថៃអីអត់ចេះដែរ?

ខ៖ អត់ចេះទាំងអស់នឹង

ក៖ បាទចុះមីងធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាអត់មីង?

ខ៖ ចាថាម៉េចដែរ?

ក៖ មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាអត់មីងមិត្តភក្តិស្និទ្ធិស្នាលហាស?

ខ៖ អត់ផងនឹង

ក៖ ប៉ុន្តែកាលពីក្មេងៗមានមិត្តភក្តិតាហ៎មីង?

ខ៖ មិត្តភក្តិពីក្មេងមានតែនៅព្រៃវែងនឹង

ក៖ គាត់មានឈ្មោះអីគេដែរមីង?

ខ៖ ឥឡូវនឹងគេមានប្តីមានប្រពន្ធអស់ហើយនឹង

កៈ
មីងអាចប្រាប់ឈ្មោះម្នាក់ទៅពីរនាក់អីក៏បានដែរតាមមីងចាំចឹងហាសឈ្មោះអីចឹងហាសមីង?

ខៈ ឈ្មោះ សុខហេង ,ឈ្មោះ អារឿន, ចាំតែប៉ុណ្ណឹដែរស្និទ្ធិមានតែពីរនាក់នឹងអែង

កៈ ចុះមីងមានចងចាំអនុស្សាវរីយ៍អីជាមួយមិត្តភក្តិរបស់មីងទេ
ធ្លាប់លេងអីជាមួយគ្នាចឹងហាស?

ខៈ នឹងហើយដូចថាធ្លាប់បបួលគ្នាទៅដកសំណាប ទៅស្ទូងទៅអី
លេងបិទពួនកាលពីក្មេងចឹងហាស

កៈ ចុះមីងមានធ្លាប់ទៅធ្វើការនៅវាលស្រែទេមីង?

ខៈ វាលស្រែមិនដែរទៅធ្វើអីទេ

កៈ ប៉ុន្តែចុះមីងធ្លាប់ទៅស្រែដកស្ទូងអីទេ?

ខៈ ធ្លាប់ធ្វើទៅដកស្ទូងអោយគេនឹង

កៈ ទៅច្រូតកាត់អីណាមីង?

ខៈ ទៅច្រូតកាត់អីអោយគេនឹងហាស?

កៈ ចុះមីងមានធ្លាប់បើកអាជីវកម្មនៅក្នុងគ្រួសារ រឺមួយក៏លក់ដូរអីទេមីង?

ខៈ កាលពីមុនខ្ញុំលក់ដូរនៅកំពុងសោមបន្តិចបន្តួច

កៈ លក់អីគេវិញមីង?

ខៈ លក់កាហ្វេ លក់ម្ហូបអាហារចឹងហាស ធ្វើជំនួញចិញ្ចឹមកូនហាស
ដល់ពេលឥឡូវនឹងកូនវានៅម្នាក់អែងនឹងវាមិនហ៊ាននៅ

កៈ អោយមីងមកនៅជាមួយ?

ខៈ វាអោយមកនៅជាមួយបានពីរនាក់វាគ្នាស្រីវាពិបាក
ដល់ចឹងទៅខ្ញុំក៏រកការងារធ្វើទៅគ្រាន់បានជួយថ្លៃផ្ទះកូនចឹងហាស

កៈ ចុះមីងធ្លាប់ចិញ្ចឹមមាន់ ជ្រូក ទា គោអីទេ?

ខៈ ខ្ញុំចិញ្ចឹមមាន់ ជ្រូកអត់ចិញ្ចឹមទេ

កៈ ប៉ុន្តែកាលពីនៅស្រុកណាមីង?

ខៈ កាលនៅកំពុងសោម

កៈ នៅសំពុងសោម មីងចិញ្ចឹមមាន់ច្រើនមែនមីង?

ខៈ ចិញ្ចឹមមាន់ច្រើនដែរតែដល់ពេលឥឡូវនឹង ដល់ពេលមកនៅនេះអស់រលីងហើយនឹង

កៈ មីងចិញ្ចឹមជាលក្ខណៈកសិដ្ឋានមែនមីង រឺក៏ចិញ្ចឹមជាលក្ខណៈគ្រួសារ ចិញ្ចឹម10-20មីង?

ខៈ ចិញ្ចឹមលក្ខណៈគ្រួសារចឹងទៅដូចថាយើងដូរដោះចឹងទៅណា ចិញ្ចឹមលក្ខណៈបួន ដប់ម្ភៃមាន់ចឹងទៅពេលណាដែរដច់លុយទៅហៅគេមកចាប់ចឹងទៅ

កៈ
ចុះមីងមានធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់មីងតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ ខ្ញុំនឹធ្វើការសំណង់ក៏ចេះធ្វើដើរធ្វើទៅអោយតែគេអោយធ្វើ
អត់មានការងារធ្វើគេហៅអោយទៅធ្វើក៏ទៅធ្វើទៅការងារអីក៏ធ្លាប់ធ្វើដែរ
នៅកំពុងសោមចឹងគេហៅអោយធ្វើអីក៏ធ្វើ
នៅចំការនឹងគេហៅការងារអីនឹងយើងធ្វើចឹងទៅ

កៈ បាទប៉ុន្តែមីងឥឡូវនឹងមីងមានធ្វើអីគេដែរមីង?

ខៈ ខ្ញុំធ្វើការនៅក្នុងហ៊ាងនឹង

កៈ អូធ្វើអីគេមីងខាងអូឌើរ?

ខៈ អត់ទេខ្ញុំខាងរៀបបន្ទប់អោយគេនឹង

កៈ អូអ្នកចំបន្ទប់ហោសមីង
ចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះដែរមីងតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង ថាពីតូចនឹងយ៉ាងម៉េចដែរ ហើយឥឡូវនឹងយ៉ាងម៉េចដែរចឹងហាស?

ខ៖ ម៉េចឈឺហោស?

ក៖ ទាំងសុខភាព នឹងទាំងជីវភាពហាស?

ខ៖ ឥឡូវនឹងខ្ញុំឈឺ ខ្វមសព្វថ្ងៃនឹងមានជំងឺប្រចាំខ្លួន

ក៖ ចុះជីវិភាណយ៉ាងម៉េចដែរមីង?

ខ៖ ជីវភាពរបស់យើងវាមធ្យមវាមិនក្រ ហើយក៏វាមិនមានដែរគ្រាន់តែថាវា

ក៖ ប៉ុន្តែវាអាចគ្រាន់ជាងកាលពីនៅតូចមែនទេមីង?

ខ៖ ចាវារៀងគ្រាន់ជាងមុនថាយើងចេះតែនេះទៅ

ក៖ ចុះម្ហូបអីដែរមីងចូលចិត្តជាងគេដែរមីង?

ខ៖ ខ្ញុំចូលចិត្តសម្លម្ជូរ

ក៖ សម្លការី កក្កូរអីមីងមានចូលចិត្តទេ?

ខ៖ ចូលចិត្តកក្កូរ

ក៖ ចុះឆា ចៀនអីមីង?

ខ៖ ឆា ចៀនក៏ចូលចិត្តដែរនឹង

ក៖ ជាពិសេសស្ងោរមាន់មីង?

ខ៖ មាន់ធ្លាប់ហូបហើយខ្ទិលហាស បើប្រហុកអានឹងវាចំណូលវិញនឹង

ក៖ ចុះល្បែងប្រជាប្រិយ៍អីដែរមីងចូលចត្តលេងហាស ដូចជាចោលឈូង បោះអង្គុញ ទាញព្រាត លាក់កន្សែងអីចឹងហាសមីងចូលចិត្តលេងទេ?

ខ៖ ចាចូលចិត្តតា

ក៖ ភាគច្រើនមីងចូលចិត្តលេងអីច្រើនជាងគេដែរមីង?

ខ៖ ចូលចិត្តលេងទាញព្រាត បោះអង្គុញ ហើមអស់ហើយក្បាលជង្គង់នឹង

ក៖ ចុះមីងធ្លាប់មានចូលចិត្តលេងដឹកដៃកូនប្រសារទេ?

ខ៖ អត់ទេ

ក៖ លក្ខណះពង្រត់ដឹកដៃគ្នាចឹងហាស?

ខ៖ អត់មានទេ

ក៖
ចុះមីងគិតថាមីងមានធ្លាប់បានរៀនច្រៀងទេតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង?

ខ៖ អត់ចេះផងអត់ចងចាំទេ

ក៖ ចុះមីងចូលចិត្តស្តាប់បទចំរៀងទេមីង?

ខ៖ ខ្ញុំចូលចិត្តស្តាប់តែល្ខោនទេ

ក៖ មីងចូលចិត្តល្ខោនណាមីង?

ខ៖ បើថាមានណាមានល្ខោនកុំបិទទាល់តែភ្លឺក៏មើលដែរនឹង

ក៖ ប៉ុន្តែចំរៀងមីងមិនសូវចូលចិត្តទេមីងចូលចិត្តមើលល្ខោនច្រើនជាង?

ខ៖ អត់ទេចូលចិត្តមើលល្ខោននឹង

ក៖ ចុះមីងមាននរណាគេនៅក្នុងគ្រួសាររបស់មីងចេះលេងឧបករណ៍ភ្លេងទេមីង
ដូចជាបងប្អូនសាច់ញ្ញាតិអីចឹងហាស?

ខ៖ អត់មានផងនឹង

ក៖ ដូចជាឧបករណ៍ខ្មែរ នឹងអ៊ីរ៉ុបអីអត់មានដែរ?

ខ៖ អត់មានទេ

ក៖
អូបាទចុះផ្ទះរបស់មីងមានលក្ខណះបែបណាដែរមីងតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង ដូចថាក្មេងនឹងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាស?

ខ៖ អូខ្ញុំកាលពីខ្ញុំនៅព្រៃវែង ផ្ទះរបស់ខ្ញុំវារៀងអន់
ដល់ពេលដល់នៅព្រៃវែងនឹងវាផ្ទះវារៀគ្រាន់បើចឹងហាស

កៈ អូចុះផ្ទះរបស់មីងនៅកំពុងសោមនឹងនរណាគេជាអ្នកសាងសងដែរមីង?

ខៈ ប្ដីរបស់ខ្ញុំនឹង

កៈ អូប្ដីរបស់មីងគាត់ចេះធ្វើផ្ទះហោសមីង?

ខៈ ចាគាត់ចេះ

កៈ ចុះគាត់ចេះមកពីនរណាគេដែរមីង?

ខៈ គាត់រៀនខ្លួនគាត់នឹង

កៈ អូគាត់មើលគេគាត់ចេះណាមីង
ចុះមីងគិតថាផ្ទះរបស់មីងនឹងធ្វើគេមានឧបករណ៍អីគេសំរាប់ធ្វើផ្ទះនឹងដែរមីង?

ខៈ គេមានស្អីៗទេម៉ាចប់នឹង

កៈ ដូចមានដែកឈូស ដែកដាប់ អីនឹង?

ខៈ នឹងហើយដែកឈូស ដែកដាប់អីរណាអីចឹងទៅ មានដែកគោលអីមួយចប់នឹង

កៈ ចុះមីងគិតថាមានជំនាញអីដែរគិតថាមីងចេះស្ទាត់ជំនាញទេ
ជំនាញអីដែរមីងគិតថាមីងចេះធ្វើខ្លួនអែងហាសមីង?

ខៈ ខ្ញុំចេះធ្វើជំនាញចេះធ្វើអំបោស

កៈ មីងចេះធ្វើអំបោសហោសមីង?

ខៈ ចាអំបោសបោសផ្ទះនឹងកាលពីក្មេងខ្ញុំធ្វើវារាល់ថ្ងៃ

កៈ ប៉ុន្តែមីងចេះស្ទាត់ខាងលក់ដូរដែរណាមីង?

ខៈ លក់ដូរក៏ចេះ

កៈ ចុះឪពូកម្ដាយរបស់មីងធ្លាប់មានបង្រៀនអីផ្សេងទៀតទៅមីងទេ
ដូចបង្រៀនធ្វើម្ហូបអីដែរគិតថាមីងធ្វើស្ទាត់ហាស?

ខៈ ធ្វើម្ហូបសម្លម្ជូរ កកូរអីចឹងទៅ ប្រហើរអីចឹងទៅចេះតែធ្វើទៅណា

កៈ ចុះជំនាញវេញវល្លិ៍ ធ្វើផ្ដៅ កូរស្ករត្នោតអីមីងមានចេះទេ?

ខ៖ ស្អូរត្នោតអត់ចេះទេ

ក៖ ចុះធ្វើផ្តៅ ធ្វើកន្ទេលអីមីងអត់ចេះទេ?

ខ៖ ធ្វើកន្ទេលមានតែខ្ញុំចាក់ អាកន្ទេលកក់មូលហាស

ក៖ បាទមីងចេះចាក់កន្ទេល នឹងមីងចេះធ្វើអំបោសណាមីង?

ខ៖ ចាចេះធ្វើអំបោស

ក៖ ចុះមីងអាចប្រាប់ខ្ញុំបានទេដែរគិតថាជាពេលដែរលំបាកនៅក្នុងជីវិតរបសមីងបានទេ?

ខ៖ ខ្ញុំពិបាកតែរហូតនឹង ទើបតែមកឥឡូវនឹងរៀងគ្រាន់បើបន្តិចនឹង

ក៖ អូកាលបីមីងនៅក្មេងនឹងតើមីងពិបាកអីគេខ្លះទៅ?

ខ៖ ពិបាកនឹងយើងអត់ ហើយយ៉ាងណាមួយយើងអត់ផ្ទះអត់សំបែង
នៅវាមិនបានស្រួលដូចកូនគេចឹងហាស

ក៖
បាទមីងចុះនៅពេលដែរកាលពីជំនាន់ពលពតមីងគិតថាមីងមានការពិបាកអីគេខ្លះដែរមីង?

ខ៖
ពលពតនៅពីក្មេងគេហៅអោយទៅលើកអាចម៍គោអាចម៍អីគេហៅអោយរត់ចេះតែរត់នឹងរត់គ្មានដឹងថាស្លាប់ រត់គ្មានដឹងថារស់ទេ

ក៖ អូពេលណុងគេអោយមីងនៅណាដែរមីង?

ខ៖ ខ្ញុំនៅព្រៃវែងណោះ

ក៖ មីងនៅព្រៃវែង ប៉ុន្តែគេអោយមីងនៅជាមួយក្រុមគ្រួសារទេ?

ខ៖ អត់ផងនឹង

ក៖ អូចុះក្រុមគ្រួសារទៅនៅណាទៅមីង?

ខ៖ គាត់មកនៅកន្លែងចុងភៅគេអោយនៅផ្ទះចឹងទៅណាគេអោយ
អោយក្មេងៗទៅនៅម្តុំចឹងទៅណា

កៈ អូបាទប៉ុន្តែមីងអត់នៅផ្ទះទេគេមិនអោយនៅផ្ទះទេ?

ខៈ នឹងហើយគេដាក់ក្មេងៗម្ដុំចឹងទៅ
ដល់ពេលនឹងទៅគេអោយបបរបន្តិចៗម្នាក់ៗចេះតែហូបចឹងទៅណាស់

កៈ លក្ខណៈថាមីងទៅតែម្នាក់អែង រឺក៏មីងទៅទាំងបងប្អូនរបស់មីងរឺមួយយ៉ាងម៉េចដែរមីង?

ខៈ ទៅក្មេងៗទាំងអស់នឹង

កៈ ទៅទាំងបងប្អូនរបស់មីងទៅដែរ?

ខៈ ចាអោយតែក្មេងគេយកទៅដាក់នៅកន្លែងនឹងទៅ

កៈ ប៉ុន្តែគេអោយយើងធ្វើអីទៅនៅណុងដែរមីង?

ខៈ អោយរើសសំរាមអីទៅ

កៈ អោយលើកអាចម៍គោណាមីង?

ខៈ អោយលើកអាចម៍គោទៅចឹងហាសណាស់ចេះតែធ្វើតាមគេចឹងទៅណា

កៈ
ចុះរបបអាហារយ៉ាងម៉េចដែរកាលណុងក្មេងៗចឹងគេអោយរបបអាហារយ៉ាងម៉េចដែរមីង?

ខៈ មានអីមានតែបបរៗហើយនឹងដំឡូងនឹងដាក់លាយគ្នានឹង
បាយដាំជាមួយដំឡូងនឹងដើមចេក ដើមល្ហុងអីនឹងចេះតែដាក់ទៅ

កៈ ចុះនៅពេលដែរដាច់ពលពតមីងធ្វើអីគេទៅមីង?

ខៈ ខ្ញុំចាប់ផ្ដើមយើងចេះតែធ្វើស្រែធ្វើចំការចឹងទៅណា ស្ទូង ដកសុីឈ្នួលអោយគេទៅ
យើងកាលណុងវាអត់ចឹងយកស្រែទោប្រចាំគេបន្តិចបន្តួចចឹងទៅលក់អស់ហើយ

កៈ
ប៉ុន្តែកាលពីជំនាន់ណុងគេនៅចាយលុយនៅឡើយតាហីមីងកាលពីដាច់ពលពតថ្មីៗហាស
មីង?

ខ៖
នឹងហើយនៅចាយលុយដល់ពេលដែរយើងចេះតែទុកមិនហ៊ានចាយរហូតទាល់តែបោះចោលទៅ

ក៖ ប៉ុន្តែកាលពីជំនាន់ណុងលុយថ្លៃហោសមីង ហើយមាសថោកណាមីង?

ខ៖ កាលណុងមាសថោក លុយថ្លៃនឹងហើយ

ក៖ ដូចជាកាលណុងមាស1ជំលឹង រឺក៏មាស1ជីដូរបានប៉ុន្មានដែរទៅមីង?

ខ៖ ខ្ញុំអត់ដឹងដែរខ្ញុំមិនចេះទិញមាសផងកាលពីនៅក្មេងនឹង

ក៖
អូចុះនៅពេលណាដែរមីងគិតថាពេលដែរមីងចាប់ផ្តើមពេញចិត្តស្រលាញ់ប្តីរបស់មីងចឹងហាស នៅឆ្នាំណាទៅមីង?

ខ៖ ប៉ុន្មានឆ្នាំទេនេះជាងកូនរបស់ខ្ញុំអាយុ18ឆ្នាំហើយ

ក៖ អាយុ18ឆ្នាំចឹងមានន័យថាឆ្នាំជិត2000ណាមីង?

ខ៖ ចឹងហើយមើលទៅ

ក៖ ចុះកាលណុងមីងអាយុប៉ុន្មានដែរទៅមីង?

ខ៖ ប៉ុន្មានទេ16ឆ្នាំមិនដឹង17ឆ្នាំមិនដឹងទេនេះខ្ញុំភ្លេចបាត់ទៅហើយ

ក៖ ចុះមីងដូចជាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរមីង?

ខ៖ ចាថាម៉េចទៅ?

ក៖ ដូចជាមីងជំនះឧបសគ្គនឹងដោយរបៀបណាដែរទៅ?

ខ៖ យើងចេះតែដើរទៅណាផ្សងព្រេងនៅនឹងគេ នៅនឹងអែងចឹងទៅ
គេអោយនៅផ្ទះគេចេះតែនៅចឹងទៅណា ហើយយើងលក់ដូរអោយគេចឹងទៅណា

ក៖ អូបាទមីងនឹងហើយជាការឆ្លងកាត់ការជំនះរបស់មីងណាមីង?

ខ៖ ចានឹងជាការជំនះនឹង

កៈ
ចុះមីងគិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់មីងដែរ?

ខៈ អត់មានពេលដែរសប្បាយទេ ឥឡូវនឹងក៏អត់មានសប្បាយចិត្តដែរនឹង

កៈ ចុះមីងគិតថានៅពេលដែរជួបជុំជាមួយក្រុមគ្រួសារអីចឹងហាសមីង?

ខៈ ជួបជុំចឹងទៅពេលនាដែរគេទៅរកលុយរកកាក់បានឆ្ងាយចឹងទៅណាវាពិបាកដែរ

កៈ ចុះមីងធ្លាប់មានក្ដីសង្ឃឹមអីគេថាកាលពីមីងនៅក្មេងៗហាស មីងមានធ្លាប់គិទេមីង?

ខៈ ខ្ញុំចង់តែទៅលក់ដូរទៅអីទេ

កៈ នេះជាការគិតរបស់មីង
មីងគិតថាពេលដែរធំឡើងមីងចង់លក់ដូរអោយស្ទាត់ជំនាន់ដែរណាមីង
ថាចង់បើកអាជីវកម្មអីមួយ?

ខៈ ខ្ញុំទៅនៅជាមួយគេគេអោយលក់ចឹងដែរ
ចង់តែលក់ចឹងទៅរាល់ថ្ងៃខ្ញុំមិនចង់ធ្វើការងារចឹងទេ បើមានលុយខ្ញុំនឹងធ្វើវា

កៈ ចុះមីងមានធ្លាប់គិតថាពេលដែរមីងធំឡើងមីងចង់ធ្វើអីជាលក្ខណៈថា ជាគ្រូពេទ្យ
គ្រូបង្រៀនមីងមានធ្លាប់គិតទេមីង?

ខៈ គិតដែរតាប៉ុន្តែយើងវាអត់លុយដែរ បានកូនមួយវាដុះ បានកូនរបស់ខ្ញុំនឹងហាស

កៈ បាទមីងកូននៅភ្នំពេញរាល់ថ្ងៃហោសមីង?

ខៈ ចាកូននៅជាមួយនឹង

កៈ ចុះកូនរបស់មីងគាត់ធ្វើអីគេដែរមីង?

ខៈ នៅរៀននឹង

កៈ ប៉ុន្តែគាត់រៀននៅសកលវិទ្យាល័យ ប៉ុន្តែបានធ្វើការងារខ្លះដែរតាហីមីង?

ខៈ ចាមិនទាន់ផងនឹង

កៈ
អូបាទមីងចុះបើសិនជាចង់អោយមីងផ្ដែផ្ដាំទោកូនចៅជំនាន់ក្រោយៗទៅមីងចង់ផ្ដែផ្ដាំងីទៅពួកគាត់ដែរមីង?

ខៈ
ចង់អោយកូនវាបានរៀនបានសូត្រកុំអោយដូចខ្ញុំពេលដែរចាស់ទៅវាពិបាកចឹងហាសវាពិបាកណាស់ ពេលដែរចេះទៅវាស្រួលរកការងារធ្វើចឹងទៅ

កៈ បាទមីងចុះមីងមានអីដែរចង់ផ្ដែផ្ដាំអីផ្សេងទៀតទេមីង
រឺមួយក៏មីងចង់អោយពួកគាត់បានសំរេចគោលបំណង់ប្រាថ្នារបស់មីងអីណាមីងមីងមានបានគិតវាទេថាពេលដែរមីងធ្វើវាអត់មានប៉ុន្តែមីងបានគិតចឹងហាសមីង?

ខៈ ចង់ងោយកូនរៀនចេះទៅ ថាម៉ែវាល្ងង់ហើយ
ពេលវារៀនចេះដឹងទៅវាងាយស្រួលបានប្ដីល្អចឹងហាស
ទៅបីយើងនៅតែម្នាក់អែងក៏យើងវាស្រួលដែរនឹង គេអាចចិញ្ចឹមខ្លួនអែងបានចឹងហាស

កៈ បាទមីងមានអីផ្សេងដែរមីងមានអីចង់ផ្ដែផ្ដាំអីទៀតទេមីង
រឺមួយក៏ចង់អោយគាត់ដើរកន្លងធិមដើរផ្លូវរបស់មីងដែរមីងធ្លាប់គិតពីមុនចឹងហាសមីង

ខៈ អោយក្មេងនៅជំនាន់នេះអោយវាដើរផ្លូវល្អចឹងហាស កុំអោយទៅផ្លូវអាក្រក់វាពិបាកនឹង

កៈ អូចឹងបាទ ចុះមានអីផ្សេងអីទៀតអីទេមីង?

ខៈ អត់មានអីទៀតទេ

កៈ បាទចឹងជាចុងក្រោយខ្ញុំអរគុណមីងដែរបានអោយខ្ញុំបានពិភាក្សាខ្ញុំ
ហើយនឹងផ្ដងពេលវេលាអោយខ្ញុំដើម្បីអោយខ្ញុំបានស្គាល់បីប្រវត្តិរបស់មីង
ហើយនឹងសំភាសន៍ពីប្រវត្តិរបស់មីងចឹងហាសមីង
ហើយការសំភាសន៍នេះត្រូវបានរៀបចំនៅខាងសាលាដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់បានស្គាល់នឹងហាស ហើយជាចុងក្រោយខ្ញុំអរគុណមីងដែរ
ហើយខ្ញុំសុំជូនពរមីងអោយមានសុខភាពល្អ អាមានសុភង្គលជាមួយកូនដែរចឹងហាសមីង
បាទចឹងអរគុណច្រើនមីង៕៕៕